ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១៥៨ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការធ្វើអនុបយោគ ប្តូរចំណាត់ថ្នាក់ ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- លិខិតលេខ ១០០០ សជណ.ដប ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- លិខិតលេខ ៩៩៩ សជណ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- លិខិតលេខ ១៣៧៨ សជណ.ឧស ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- លិខិតលេខ ១៣៣៧ លស.អរហ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៩ របស់ក្រសួងទេសចរណ៍
- លិខិតលេខ ១០១៨ លស ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៩ របស់ក្រសួងទេសចរណ៍។

## សម្រេច

**មាត្រា ១.-**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ នូវទីតាំងដីទំហំ ៣០០(បីរយ) ហិកតា ស្ថិតនៅតំបន់ភ្នំដូង ក្នុងភូមិបឹងតាព្រាម សង្កាត់ត្រើយកោះ ក្រុងកំពត ខេត្តកំពត ដែលមានផែនទីគំនូសប្លង់ទីតាំងក្បាលដី និងនិយាមការ កំណត់ដោយគណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា ជាឧបសម្ព័ន្ធនៃការអភិវឌ្ឍគម្រោងទេសចរណ៍ "ហង្សរាជ្យ" នេះ។

**មាត្រា២.-**

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគដូចបានកំណត់ក្នុងមាត្រា១ នៃអនុក្រឹត្យនេះ ត្រូវស្ថិតនៅក្រោមការចាត់ចែងនីតិវិធីបន្តដោយក្រសួងទេសចរណ៍ ដែលជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់បទប្បញ្ញត្តិពាក់ព័ន្ធ និងគោលការណ៍កំណត់របស់រាជរដ្ឋាភិបាល។

**មាត្រា ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ជាទុកជានិរាករណ៍។

**មាត្រា ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រី គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃព្រហស្បតិ៍ ៤ កើតខែ កត្តិក ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ២០១៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- ឯកសារ-កាលប្បវត្តិ

ផែនទីបង្ហាញក្បាលដីគម្រោងអភិវឌ្ឍន៍ទេសចរណ៍ "ហង្សរាជ" ស្ថិតនៅភូមិបឹងតាព្រាម សង្កាត់ត្រើយកោះ ក្រុងកំពត ខេត្តកំពត




តារាងនិយាមកាព្រំដី
Projection, UTM, Zone 48N
Daum, WGS, 1984

| ID | E | N | ID | E | N |
|---|---|---|---|---|---|
| 1 | 409854.642 | 1165326.654 | 44 | 408800.211 | 1165537.737 |
| 2 | 409867.409 | 1165364.244 | 45 | 408687.265 | 1165447.062 |
| 3 | 409865.724 | 1165394.156 | 46 | 408637.153 | 1165417.976 |
| 4 | 409858.165 | 1165417.590 | 47 | 408549.308 | 1165357.148 |
| 5 | 409845.314 | 1165431.197 | 48 | 408505.834 | 1165316.261 |
| 6 | 409801.138 | 1165459.004 | 49 | 408468.792 | 1165281.425 |
| 7 | 409758.999 | 1165503.809 | 50 | 408408.153 | 1165224.395 |
| 8 | 409743.505 | 1165535.984 | 51 | 408351.557 | 1165132.233 |
| 9 | 409734.861 | 1165576.755 | 52 | 408296.218 | 1165028.791 |
| 10 | 409735.117 | 1165597.182 | 53 | 408259.995 | 1164935.502 |
| 11 | 409737.839 | 1165620.767 | 54 | 408233.964 | 1164809.248 |
| 12 | 409740.783 | 1165635.909 | 55 | 408213.967 | 1164676.487 |
| 13 | 409741.962 | 1165647.693 | 56 | 408214.516 | 1164508.443 |
| 14 | 409739.325 | 1165668.649 | 57 | 408229.842 | 1164393.005 |
| 15 | 409725.495 | 1165685.500 | 58 | 408254.789 | 1164279.611 |
| 16 | 409706.596 | 1165691.170 | 59 | 408300.339 | 1164171.458 |
| 17 | 409689.965 | 1165686.256 | 60 | 408361.378 | 1164072.858 |
| 18 | 409676.441 | 1165680.043 | 61 | 408458.896 | 1163973.450 |
| 19 | 409566.238 | 1165562.216 | 62 | 408583.629 | 1163885.004 |
| 20 | 409521.166 | 1165534.068 | 63 | 408694.754 | 1163816.967 |
| 21 | 409475.710 | 1165517.407 | 64 | 408821.754 | 1163760.271 |
| 22 | 409424.682 | 1165510.464 | 65 | 408956.692 | 1163715.670 |
| 23 | 409337.980 | 1165518.072 | 66 | 409157.397 | 1163676.360 |
| 24 | 409312.101 | 1165525.214 | 67 | 409341.094 | 1163662.753 |
| 25 | 409249.891 | 1165553.189 | 68 | 409506.648 | 1163662.753 |
| 26 | 409183.977 | 1165597.192 | 69 | 409705.278 | 1163697.726 |
| 27 | 409161.397 | 1165622.582 | 70 | 409826.417 | 1163739.860 |
| 28 | 409138.842 | 1165659.957 | 71 | 409976.096 | 1163830.575 |
| 29 | 409130.546 | 1165685.490 | 72 | 410046.541 | 1163905.075 |
| 30 | 409128.233 | 1165724.071 | 73 | 410109.899 | 1163982.522 |
| 31 | 409130.639 | 1165749.260 | 74 | 410166.498 | 1164072.483 |
| 32 | 409138.468 | 1165783.933 | 75 | 410201.471 | 1164178.656 |
| 33 | 409144.275 | 1165818.965 | 76 | 410214.221 | 1164279.611 |
| 34 | 409140.093 | 1165855.157 | 77 | 410193.810 | 1164390.737 |
| 35 | 409142.071 | 1165909.237 | 78 | 410152.839 | 1164473.997 |
| 36 | 409129.948 | 1165955.561 | 79 | 410096.292 | 1164547.219 |
| 37 | 409120.261 | 1165978.872 | 80 | 410007.004 | 1164607.326 |
| 38 | 409099.162 | 1165993.418 | 81 | 409887.110 | 1164727.220 |
| 39 | 409069.680 | 1165998.593 | 82 | 409826.717 | 1164784.932 |
| 40 | 409040.657 | 1165980.625 | 83 | 409774.556 | 1164864.307 |
| 41 | 409016.610 | 1165946.934 | 84 | 409738.003 | 1165000.379 |
| 42 | 409004.182 | 1165921.893 | 85 | 409794.146 | 1165147.790 |
| 43 | 408915.249 | 1165701.242 | 86 | 409799.503 | 1165240.773 |